# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាបុណ្យព្រះវិញ្ញាណយាងមកនៅព្រះសហគមន៍សន្តីម៉ារីញញឹម
# ចំការទៀង ថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០២០
# លើកលែងទោសណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី

**អត្ថបទទី១៖ កិច្ចការ ២,១-១១**

ចុះហេតុដូចម្តេចបានជាយើងឮគេនិយាយភាសារបស់យើងរៀងៗខ្លួនទៅវិញដូច្នេះ? កក ២,៨

**អត្ថបទទី២៖ កូរិនថូស ទី១ ១២,៣-៧.១២-១៣**

ព្រះវិញ្ញាណប្រោសប្រទានឲ្យម្នាក់ៗសម្តែងព្រះអំណោយទាន ដើម្បីជាប្រយោជន៍រួម។ ១ករ ១២,៧

**ដំណឹងល្អ៖ យ៉ូហាន ២០,១៩-២៣**

បើអ្នករាល់គ្នាលើកលែងទោសអ្នកណាឲ្យរួចពីបាប ព្រះជាម្ចាស់ក៏នឹងលើកលែងទោសអ្នកនោះឲ្យរួចពីបាបដែរ។ យហ ២០,២៣

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ យើងស្តាប់ព្រះយេស៊ូដែលមានព្រះបន្ទូលថា "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**" នេះជាព្រះបន្ទូលដែលយើងចង់ស្តាប់មែនទែន។ នៅក្នុងបរិយាកាសនៃពិភពលោកសព្វថ្ងៃ ដែលនៅតែបន្តភ្ជាប់ជាមួយជំងឺកូវីដ១៩ បានណែនាំឲ្យបងប្អូនទូទាំងពិភពលោក និងនៅប្រទេសកម្ពុជាយើង កំពុងមើលឃើញឥទ្ធិពលដ៏អាក្រក់នៅក្នុងជីវិតប្រចាំថ្ងៃដោយសារជំងឺនេះ។ យើងចង់ស្តាប់ហើយស្តាប់ទៀត "**សូមឲ្យអ្នករាល់គ្នាបានប្រកបដោយសេចក្តីសុខសាន្ត**" ថ្ងៃនេះជាថ្ងៃដែលព្រះយេស៊ូយាងមក ដើម្បីផ្លុំលើពួកយើងទាំងមានព្រះបន្ទូលថា "**ចូរទទួលព្រះវិញ្ញាណ ឱព្រះវិញ្ញាណដ៏វិសុទ្ធសូមយាងមក**" ជាអ្វីដែលយើងចង់បានសម្រាប់ពិភពលោករបស់យើង។

ក្នុងរយៈពេល២២ឆ្នាំជាបូជាចារ្យ ១០ឆ្នាំជាអភិបាល ជាលើកទីមួយដែលខ្ញុំបានថ្វាយអភិបូជាបុណ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក នៅក្នុងបរិយាកាសស្ងាត់ដូចនេះ។ យើងនៅគ្នាតិចបំផុត យើងត្រូវតែផ្សាយផ្ទាល់ដើម្បីឲ្យបងប្អូនអាចចូលរួមអភិបូជា នៅក្នុងភូមិភាគរបស់យើងទាំងមូល យ៉ាងតិចតាម YouTube ឬ Facebook។ ជារៀងរាល់ឆ្នាំ យើងមានអភិបូជាធំណាស់ ដោយសារព្រះវិញ្ញាណដ៏វិសុទ្ធយាងមក ជាពេលវេលាដែលយើងសុំឲ្យមនុស្សទាំងអស់ទៅជាគ្រួសារតែមួយ។ រាល់ឆ្នាំ យើងបានប្រមូលអ្នកដែលនិយាយភាសាអង់គ្លេស បារាំង អ៊ីតាលី ចិន វៀតណាម ថៃ កូរ៉េ

... រួមជាមួយបងប្អូនខ្មែរយើងរាប់ពាន់នាក់ ដើម្បីសុំឲ្យព្រះវិញ្ញាណដ៏វិសុទ្ធយាងមក។ យើងចូលនៅក្នុងរដូវដែលត្រូវធ្វើអគ្គសញ្ញាលាបថ្វាស នេះជាតួនាទីរបស់លោកអភិបាល។

ថ្ងៃនេះ ខ្ញុំសូមស្វាគមន៍បងប្អូនទាំងអស់ និងស្វាគមន៍សហគមន៍និយាយភាសានានា ដែលយើងមាននៅក្នុងភូមិភាគភ្នំពេញ។ អត្ថបទទីមួយដែលយើងបានស្តាប់ យើងឃើញសញ្ញាសម្គាល់ធម្មតាបំផុត សញ្ញាដែលទាក់ទងនឹងធម្មជាតិ។ យើងបានឃើញ "**ស្រាប់តែមានឮស្នូរសន្ធឹកពីលើមេឃ ដូចខ្យល់បក់បោកយ៉ាងខ្លាំងពេញក្នុងផ្ទះដែលគេនៅ និងមានអណ្តាតភ្លើងបែកចេញពីគ្នា**"។ មានខ្យល់ដែលបានបក់យ៉ាងខ្លាំង ឮសំលេងមកពីលើ និងមានអណ្តាតភ្លើង ប្រសិនបើយើងគិតអំពីព្រះវិញ្ញាណដ៏វិសុទ្ធ យើងនឹកឃើញដល់ព្រះយេស៊ូទទួលពិធីជ្រមុជទឹក។ នៅពេលព្រះវិញ្ញាណដ៏វិសុទ្ធចុះមកលើព្រះយេស៊ូ មានព្រាបសជាសញ្ញា និងផ្ទៃមេឃហែកជាពីរ។ ជីវិតរបស់យើងត្រូវការមានសញ្ញា ព្រះជាម្ចាស់បានយល់យ៉ាងច្បាស់ នៅក្នុងសម្ពន្ធមេត្រីចាស់ មនុស្សយើងចេះតែដើរជាមួយព្រះយេស៊ូ ជួនកាលរអ៊ូរទាំ ជួនកាលរករឿងព្រះជាម្ចាស់ តែព្រះអង្គយល់យ៉ាងច្បាស់។ ព្រះជាម្ចាស់ដែលជាព្រះបិតា ដែលស្រឡាញ់មនុស្សលោក បានរៀបចំសញ្ញាសម្គាល់មួយពិសេសបំផុត ដើម្បីឲ្យមនុស្សមើលឃើញព្រះយេស៊ូផ្ទាល់។ នៅពេលនោះ គឺព្រះជាម្ចាស់បានចាប់កំណើតជាមនុស្សនៅក្នុងព្រះយេស៊ូ នេះជាសញ្ញាសម្គាល់ពិសេសរបស់ព្រះជាម្ចាស់សម្រាប់យើង គឺវត្តមានរបស់ព្រះយេស៊ូនៅក្នុងពិភពលោកនេះ។

យើងឃើញសញ្ញានីមួយៗមានអត្ថន័យ ពេលយើងនឹកឃើញដល់ព្រះវិញ្ញាណដ៏វិសុទ្ធ នឹកឃើញដល់ខ្យល់ដែលជាកម្លាំងជម្រុញយើង។ ខ្យល់ជាកម្លាំងមួយ ដែលណែនាំឲ្យស្លឹកឈើមានចលនា ខ្យល់នៃព្រះវិញ្ញាណដ៏វិសុទ្ធជម្រុញយើងឲ្យយើងទៅមុខ។ ព្រាបសដែលចុះពីស្ថានបរមសុខ ជាសញ្ញាសម្គាល់នៃសេចក្តីសុខសាន្តដែលយើងស្តាប់នៅថ្ងៃនេះ។ អណ្តាតភ្លើងដែលចុះពីលើ ជាអណ្តាតភ្លើងដែលណែនាំឲ្យយើងមានជីវិត ណែនាំឲ្យយើងពោរពេញដោយសេចក្តីស្រឡាញ់ ណែនាំឲ្យយើងពោរពេញដោយភាពកក់ក្តៅដែលមកពីព្រះជាម្ចាស់។ បងប្អូនដែលកំពុងមើលយើងតាម YouTube ឬ Facebook សូមចាប់អារម្មណ៍នៅក្នុងអណ្តាតភ្លើងនីមួយៗ យើងបានដាក់ឈ្មោះមណ្ឌលសកម្មភាពរបស់យើង។ មណ្ឌលសកម្មភាពនីមួយៗភ្ជាប់ជាមួយផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធគឺ៖

- មណ្ឌលសកម្មភាពកំពត-កែប គឺអំណរ
- មណ្ឌលសកម្មភាពទន្លេបាសាក់ គឺចិត្តស្លូតបូត
- មណ្ឌលសកម្មភាពទន្លេមេគង្គ គឺជំនឿ
- មណ្ឌលសកម្មភាពតាកែវ គឺសេចក្តីសុខសាន្ត

- មណ្ឌលសកម្មភាពភ្នំពេញថ្មី គឺសេចក្តីស្រឡាញ់
- មណ្ឌលសកម្មភាពភ្នំពេញខាងត្បូង គឺចិត្តសប្បុរស
- មណ្ឌលសកម្មភាពភ្នំពេញខាងជើង គឺចិត្តសន្តោសមេត្តា
- មណ្ឌលសកម្មភាពតាខ្មៅ គឺចេះទប់ចិត្តខ្លួនឯង
- មណ្ឌលសកម្មភាពកំពង់សោម គឺចិត្តអត់ធ្មត់។

មណ្ឌលសកម្មភាពនីមួយៗ បានទទួលអំណោយមួយ បានទទួលផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធមួយ។ សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិក យើងត្រូវការមានសញ្ញាថែមទៀត នេះជាការឈឺចាប់របស់យើងនៅក្នុងរដូវកូវីដ១៩នេះ ដែលធ្វើឲ្យយើងមិនអាចចូលពិធីបុណ្យអភិបូជា ដែលយើងមិនអាចធ្វើពិធីជ្រមុជទឹក ដែលយើងមិនអាចធ្វើពិធីលាបថ្វាស។ អគ្គសញ្ញានីមួយៗ ជាសញ្ញាខ្ពស់បំផុតរបស់ព្រះជាម្ចាស់លើជីវិតយើង។ ទឹកជាសញ្ញានៃជីវិតពេលយើងទទួលពិធីជ្រមុជទឹក នំប៉័ងជាសញ្ញានៃព្រះកាយព្រះគ្រីស្ត នៅពេលយើងថ្វាយសក្ការៈបូជារបស់គ្រីស្ត និងប្រេងជាប្រេងដែលផ្តល់កម្លាំងកាយកម្លាំងចិត្ត យើងទទួលពេលអគ្គសញ្ញាជ្រមុជទឹកផង ពេលអគ្គសញ្ញាលាបថ្វាសផង ពេលតែងតាំងបូជាចារ្យផង ពេលលាបដល់អ្នកជំងឺផង...។ នេះជាប្រេង ប៉ុន្តែជាសញ្ញានៃវត្តមានរបស់ព្រះជាម្ចាស់ នេះជាការឈឺចាប់របស់យើងមែនទែន ដែលយើងមិនបានទទួល។

ប៉ុន្មានថ្ងៃមុន ខ្ញុំបានជួបជាមួយរដ្ឋមន្ត្រីក្រសួងធម្មការ និងសាសនា ខ្ញុំបានខិតខំពន្យល់ដល់រដ្ឋមន្ត្រី សម្រាប់យើងដែលជាគ្រីស្តបរិស័ទកាតូលិក អគ្គសញ្ញានីមួយៗ អភិបូជា ពិធីបុណ្យនានា មានសារសំខាន់ដើម្បីចិញ្ចឹមជីវិតរបស់យើង។ ប្រសិនបើ យើងមិនបានទទួលអគ្គសញ្ញានីមួយៗយូរពេក ធ្វើឲ្យជីវិតរបស់យើងជាគ្រីស្តបរិស័ទស្វិតទៅៗ។ ដូចដើមឈើមួយ ពេលអស់ទឹកមែករបស់វាចាប់ផ្តើមស្វិត គល់នៅមាន ប៉ុន្តែមែកតូចៗស្វិតមុនគេបង្អស់។ ប្រសិនបើ ក្នុងចំណោមយើងជាគ្រីស្តបរិស័ទមិនទាន់រឹងមាំ ពេលអស់ទឹកដែលផ្តល់ជីវិត ពេលអស់ទឹកដែលណែនាំឲ្យយើងមានកម្លាំង ជីវិតរបស់យើងខាងផ្លូវវិញ្ញាណទៅដល់ណា មិនតែស្វិតគឺងាប់តែម្តង ដែលយើងពិបាកធ្វើឲ្យរស់ឡើងវិញ។

បងប្អូនជាទីស្រឡាញ់ យើងបន្តអធិដ្ឋានដើម្បីឲ្យព្រះវិញ្ញាណដ៏វិសុទ្ធបំភ្លឺយើង ដើម្បីព្រះវិញ្ញាណដ៏វិសុទ្ធរកមធ្យោបាយ ឲ្យយើងអាចទទួលអគ្គសញ្ញានីមួយៗ។ ពីដើមព្រះយេស៊ូបានធ្វើសញ្ញាច្រើនឲ្យមើលឃើញ បានប្រែទឹកជាស្រាដើម្បីបម្រើភ្ញៀវក្នុងរោងការបានពោរពេញដោយអំណរសប្បាយ បានណែនាំឲ្យអ្នកជំងឺ ជនពិការ បានជាសះស្បើយ...។ ប៉ុន្តែ សញ្ញាមិនទាន់ល្មមទេ យើងត្រូវការមានព្រះបន្ទូលថែមទៀត ជាពិសេសព្រះបន្ទូលដែលផ្តល់ជីវិត។ បន្តិចទៀត ពេល

ខ្ញុំនៅតុអាសនៈខ្ញុំបានយកនំប៉័ង ហើយខ្ញុំនិយាយដូចព្រះយេស៊ូពីដើម "**នេះជារូបកាយរបស់ខ្ញុំ នេះជាលោហិតរបស់ខ្ញុំ**"។ ព្រះបន្ទូលណែនាំឲ្យយើងទទួលនំប៉័ងទៅជារូបកាយមែន ស្រាទៅជាព្រះលោហិតមែន ព្រះបន្ទូលមហាកំពូលដែលយើងត្រូវតែស្តាប់ថែមទៀតគឺ "**ខ្ញុំលើកលែងទោសឲ្យ**" នេះជាអំណាចដែលយើងបានទទួលថ្ងៃនេះ។ ប្រសិនបើ យើងលើកលែងទោសឲ្យនរណាម្នាក់ ព្រះជាម្ចាស់លើកលែងទោសឲ្យយើងដែរ។ លើកលែងទោសណែនាំឲ្យជីវិតរបស់យើងទៅជាជីវិតថ្មី ណែនាំឲ្យជីវិតរបស់យើងប្រកបដោយសេចក្តីសុខសាន្ត។

ខ្ញុំគិតថាជំងឺកូវីដ១៩នេះ ជាសញ្ញាសម្គាល់មួយសម្រាប់ពិភពលោកយើង ប៉ុន្មានពាន់ឆ្នាំមុន មនុស្សយើងបានសុខចិត្តរួមគ្នាដោយនិយាយភាសាតែមួយ។ ដែលណែនាំឲ្យគេគិតថាមនុស្សយើងមានអំណាចណាស់ ដើម្បីបង្ហាញអំណាចនេះគេបានរួមគ្នាសាងសង់កំពូលមួយខ្ពស់បំផុត បញ្ជាក់ថាមនុស្សយើងមានអំណាចលើសព្រះជាម្ចាស់។ ប៉ុន្តែ ព្រះជាម្ចាស់ដែលពោរពេញដោយឫទ្ធានុភាពសព្វប្រការ នៅពេលព្រះអង្គទតឃើញដូចនេះទ្រង់បានណែនាំឲ្យមនុស្សបាក់បែកគ្នា និយាយភាសាផ្សេងៗពីគ្នា។ នៅថ្ងៃបុណ្យទី៥០ដែលយើងគោរពអំបាញ់មិញ នៅពេលនោះមានគ្រប់ជនជាតិ គ្រប់ភាសាគេនៅទីក្រុងយេរ៉ូសាឡឹម ប៉ុន្តែដោយសារព្រះវិញ្ញាណដ៏វិសុទ្ធគេស្តាប់គ្នាបាន។ មិនណែនាំឲ្យគេនិយាយភាសាតែមួយ ប៉ុន្តែគេយល់ចិត្តគ្នាបាន។ ពីដើមយើងចង់ឈ្នះព្រះជាម្ចាស់ ប៉ុន្តែព្រះអង្គបានបំផ្លាញគម្រោងការនេះ។ ថ្ងៃនេះព្រះជាម្ចាស់ បានណែនាំឲ្យយើងជាអង្គតែមួយនៅក្នុងពិភពលោក មិនមែនដោយនិយាយភាសាតែមួយ មិនមែនដោយបង្ហាញអំណាច តែដើម្បីបង្ហាញថាយើងជាគ្រួសារដែលចេះយល់ចិត្តគ្នា ដែលចេះទទួលភាពខុសៗគ្នានៅក្នុងគ្រួសារតែមួយ។ ពិភពលោកយើងសព្វថ្ងៃ មិនបានរត់ដើម្បីបង្ហាញសេចក្តីស្រឡាញ់ដល់អ្នកក្រីក្រ មិនបានរត់ដើម្បីបង្ហាញធម៌មេត្តាករុណាដល់អ្នកតូចតាច ប៉ុន្តែរត់ដើម្បីមានទ្រព្យសម្បត្តិច្រើនទៅៗ។ បង្កើតសង្គ្រាមរបៀបថ្មី នៅក្នុងប៉ុន្មានឆ្នាំកន្លងមកមិនមែនតែជាសង្គ្រាមបាញ់គ្នា គឺសង្គ្រាមសេដ្ឋកិច្ច។ នេះជាសង្គ្រាមថ្មី ដែលណែនាំឲ្យយើងផលិតឧបករណ៍ទំនើបច្រើនទៅៗ ឲ្យយើងប្រមូលទ្រព្យសម្បត្តិច្រើនទៅៗ នៅតាមប្រទេសនីមួយៗចង់ឈ្នះគេដោយខិតខំសាងសង់អាគារដែលខ្ពស់ជាងគេ។

កូវីដ១៩ ជាឱកាសមួយដើម្បីគិតអ្វីដែលសំខាន់បំផុត គឺមនុស្សលោក នេះជាពេលវេលាមួយសម្រាប់យើងម្នាក់ៗ យើងជាអ្នកមានក្តី ជាអ្នកក្រីក្រក្តី ឲ្យយើងអង្គុយដើម្បីមើលនៅក្នុងជីវិតរបស់យើងផ្ទាល់ **តើមានសញ្ញាអ្វីខ្លះដែលណែនាំឲ្យយើងមានសេចក្តីសុខ?** នៅក្នុងពិភពលោកទាំងមូល **តើមានអ្វីខ្លះដែលណែនាំឲ្យយើងមានសេចក្តីសង្ឃឹម?** ផ្លែនៃព្រះវិញ្ញាណដ៏វិសុទ្ធដែលមានថ្ងៃនេះជាមូលដ្ឋាន ជំនឿ អំណរ សេចក្តីស្រឡាញ់ ចិត្តបរិសុទ្ធ ចិត្តអត់ធ្មត់ ចិត្តប្រណីសន្តោស

... ជាផ្លែដែលអាចណែនាំឲ្យយើងសាងសង់ពិភពថ្មី។ ដោយសារកូវីដ១៩ ធ្វើឲ្យប្រជាជននៅទូទាំងពិភពលោកបាត់បង់ការងារធ្វើច្រើនណាស់ ដែលណែនាំឲ្យពិភពលោកត្រូវការគិតសាជាថ្មី **តើយើងត្រូវទីពឹងលើអ្វី? តើយើងចង់សាងសង់អ្វីខ្លះ? តើយើងចង់បន្តសាងសង់កំពូលមួយដើម្បីបង្ហាញអំណាចនៅក្នុងទ្រព្យសម្បត្តិ អំណាចនៅក្នុងបច្ចេកទេស?** ដើម្បីការពារការឆ្លងជំងឺកូវីដ១៩ យើងមិនទាន់មានថ្នាំបង្ការ ឬថ្នាំព្យាបាលទេ តែយើងរកមធ្យោបាយតែមួយគឺ គោរពគ្នាទៅវិញទៅមក (គោរពអនាម័យ រក្សាគំលាតពីគ្នា...)។

ឲ្យយើងគិតផ្ទាល់ខ្លួន ជាប្ដីប្រពន្ធកូន ជាក្រុមគ្រួសារនីមួយៗ ដើម្បីពិចារណា **តើជីវិតរបស់ខ្ញុំទៅណា?** ថ្ងៃនេះ ខ្ញុំបានអនុញ្ញាតឲ្យមានពិធីជ្រមុជទឹកនៅកន្លែងបងស្រីមេត្តាករុណាចោមចៅមាន៧នាក់ដែលបានត្រៀមខ្លួនមានចាស់ជរា មានអ្នកដែលមិនសូវចេះអាន មិនសូវយល់ ប៉ុន្តែរាល់ថ្ងៃគេបានចូលអភិបូជា អធិដ្ឋានជាមួយបងស្រី។ គេសប្បាយចិត្តណាស់ ដោយសារថ្ងៃនេះគេបានទទួលជីវិតថ្មីពីព្រះជាម្ចាស់ ពួកគាត់មិនគិតអំពីទ្រព្យសម្បត្តិឬអ្វីៗផ្សេងទេ គាត់គិតតែអំពីជីវិតពីមួយថ្ងៃទៅមួយថ្ងៃ ដោយយល់ថាមានបងស្រីដែលស្រឡាញ់គេ គេមានគ្រួសារថ្មីមួយដែលចេះស្រឡាញ់គេ ដោយសារគ្រួសារបង្កើតបានចោលគេអស់ហើយ។ នៅវត្តអង្គមន្ត្រី បានរៀបចំកន្លែងដាំបន្លែធម្មជាតិ ពេលខ្ញុំឃើញទាំងកូននេន ទាំងចៅអធិការ ទាំងគណកម្មការវត្តទាំងគណកម្មការព្រះសហគមន៍ កំពុងរៀបចំដី កំពុងធ្វើការរួមគ្នា ខិតខំថែរក្សាបន្លែរួមគ្នា ដូចជាគ្រួសារតែមួយ នេះជាពិភពលោកដែលយើងចង់បាន។ ថ្ងៃស្អែក យើងគោរពថ្ងៃទី០១ ខែមិថុនាជាទិវាកុមារអន្តរជាតិ តាមរយៈក្រុមយុវជន ក្រុមកាយឫទ្ធិយើងបានរៀបចំកម្មវិធីដើម្បីឲ្យកូនក្មេងមានសេចក្ដីសុខ ឲ្យនឹកឃើញសិទ្ធិរបស់គាត់ជាពិសេសនៅក្នុងរដូវកូវីដ១៩នេះ ដែលណែនាំឲ្យគេទៅសាលាមិនបាន។ ពីមួយអាទិត្យទៅមួយអាទិត្យ ពេលខ្ញុំឃើញក្រុមគ្រីស្តទូតរបស់យើងបានទៅដល់ផ្ទះបងប្អូន ទៅជួបយាយ ជួបយុវជន ជួបកូនក្មេង ដើម្បីអានគម្ពីរ ដើម្បីអធិដ្ឋានតាមផ្ទះ នេះជាអ្វីដែលព្រះជាម្ចាស់ចង់បានសម្រាប់យើង។ គ្មានកំពូលយ៉ាងខ្ពស់ គ្មានអ្វីអស្ចារ្យ សុទ្ធតែជាសញ្ញាតូចៗដែលណែនាំឲ្យយើងមើលឃើញទុកជាមុន សញ្ញាសម្គាល់នៃពិភពថ្មីដែលព្រះជាម្ចាស់បានរៀបចំ។ យើងបានឃើញ ព្រះវិញ្ញាណដ៏វិសុទ្ធដែលកំពុងយាងចុះលើផែនដីរបស់យើង ដើម្បីសាងសង់មនុស្សលោកថ្មី ដើម្បីសាងសង់សង្គមថ្មីនៅក្នុងព្រះវិញ្ញាណដ៏វិសុទ្ធ។ សូមព្រះវិញ្ញាណដ៏វិសុទ្ធយាងមក សូមព្រះវិញ្ញាណដ៏វិសុទ្ធប្រទានសេចក្ដីសុខសាន្តឲ្យយើងទាំងអស់គ្នា។ អាម៉ែន៕